ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ១១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

**Work Activities**

ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាច្រកម្ពុជា | ១ |
| ២- | សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ឆ្នាំ២០១១-២០២៥ | ៣ |
| ៣- | សេចក្តីព្រាងអនុក្រឹត្យស្តីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក សម្រាប់សិស្ស-និស្សិតសិក្សាតាមគ្រឹះស្ថានសាធារណៈ | ៥ |
| ៤- | កិច្ចប្រជុំចុងក្រោយស្តីពី៖<br>ក- សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យ នៅជនបទឆ្នាំ ២០១៤-២០២៥។<br>ខ- សេចក្តីព្រាងច្បាប់ ស្តីពីការអនុវត្តម៍តយល់ព្រមលើការសន្យាទូទាត់ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុន ស៊ីធីលុម អេសអេ។ | ៦ |
| ៥- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែតុលា ឆ្នាំ២០១៣ | ៧ |
| ៦- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេសរយៈពេល ០៥ថ្ងៃ មានចំនួន ០៩លើក នៅក្នុងឆ្នាំ២០១៣ ក្រោមអធិបតីភាព ឯកឧត្តម **ហុង ថា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC)និង ឯកឧត្តម **អ៊ុក រី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ។



កន្លងទៅរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងគ្រប់គ្រងត្រួតពិនិត្យរាល់សកម្មភាពចេញចូលព្រះរាជាណាចក្រកម្ពុជា របស់អ្នកដំណើរមធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ ដើម្បីធានាឲ្យមានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ និងធានាដល់ការធ្វើអាជីវកម្ម និងសេវាកម្មប្រកបដោយជំនឿទុកចិត្ត។

បន្ទាប់មក ដើម្បីបង្កើនការគ្រប់គ្រងនៅច្រកចេញចូលអាកាសយានដ្ឋានអន្តរជាតិនៅផ្ទៃក្នុងប្រទេស ដែលជាច្រកទ្វារអន្តរជាតិឲ្យកាន់តែប្រសើរឡើងថែមទៀតក្នុងការធានាសន្តិសុខ និងសុវត្ថិភាពដល់កិច្ចប្រតិបត្តិការវិស័យអាកាសចរស៊ីវិល រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយបានបង្កើតឡើងនូវគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិមួយដែលមានរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ជាប្រធាន ដែលផ្តាច់ចេញពីអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១។

នៅឆ្នាំ២០០៧ ច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា បានចូលជាធរមាន។

នៅឆ្នាំ២០០៨ អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ(ICAO) បានចុះធ្វើសវនកម្មលើការងារសន្តិសុខនៅព្រះរាជាណាចក្រកម្ពុជា បានបង្ហាញថា ការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិលនៅព្រះរាជាណាចក្រកម្ពុជា នៅមានកម្រិត មិនទាន់ឆ្លើយតបតាមលក្ខខ័ណ្ឌស្តង់ដា និងតម្រូវការរបស់អង្គការអាកាសចរណ៍អន្តរជាតិនៅឡើយ ជាពិសេស ក្នុងការរៀបចំបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិល។

ដើម្បីបំពេញកង្វះខាតខាងលើ នឹងក្នុងនាមព្រះរាជាណាចក្រកម្ពុជា ជាសមាជិករបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ គណកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ រួមជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណង៖

-ឲ្យស្របតាមខ្លឹមសារស្តង់ដា និងបទដ្ឋានគតិយុត្ត ស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិលរបស់អង្គការ ICAO

-រក្សាការពារសន្តិសុខសណ្តាប់ធ្នាប់និងសុវត្ថិភាពជូនអ្នកដំណើរ និងក្រុមការងារដែលបម្រើឲ្យវិស័យអាកាសចរណ៍ស៊ីវិល ប្រកបដោយទំនុកចិត្ត និងមានលក្ខណៈសេដ្ឋកិច្ច

-អនុវត្តប្រឆាំងទប់ទល់នឹងអំពើរំលោភបំពានដោយខុសច្បាប់ និងការបង្ករភេរវកម្ម(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

## សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពី

# វិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ឆ្នាំ២០១១-២០២៥

កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ឆ្នាំ២០១១-២០២៥** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអភិវឌ្ឍន៍ជនបទ។



ក្រសួងអភិវឌ្ឍន៍ជនបទ បានរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ឆ្នាំ ២០១១-២០២៥ ក្នុងគោលបំណងលើកកម្ពស់សុខភាពសាធារណៈ និងអាហារូបត្ថម្ភរបស់ប្រជាពលរដ្ឋជនបទ តាមរយៈការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ។ គោលបំណងសំខាន់ គឺពន្លឿនការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ២០១៥ និងសម្រេចបាននូវទស្សនវិស័យរបស់វិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ឆ្នាំ២០២៥។

ផែនការយុទ្ធសាស្ត្រជាតិនេះ នឹងត្រូវបានប្រើប្រាស់ដោយស្ថាប័នគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធរួមមានស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងវិស័យឯកជន។ វិស័យនេះមានដំណើរការទៅតាមលំដាប់ថ្នាក់ខុសៗគ្នាមួយចំនួនដូចជា កម្រិតគ្រួសារ និងសហគមន៍ កម្រិតថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ។ នៅតាមលំដាប់ថ្នាក់នីមួយៗ មានអ្នកអនុវត្ត ភាគីពាក់ព័ន្ធព្រមទាំងបុគ្គលផ្សេងៗគ្នាជាច្រើន ដែលពួកគេម្នាក់ៗមានទស្សនៈ និងមតិយោបល់ផ្សេងៗគ្នា។ ទស្សនៈ និងមតិយោបល់ផ្សេងៗទាំងអស់នេះ បូកបញ្ចូលគ្នាបានធ្វើឲ្យវិស័យនេះ ជាវិស័យដែលមានលក្ខណៈស្មុគ្រស្មាញ

# កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល



ទាំងគុណតម្លៃ ទាំងការយល់ដឹងពីបញ្ហាប្រឈម ប្រព័ន្ធ និងដំណើរការ ក៏ដូចជាការយល់ដឹងពីមធ្យោបាយក្នុងការដោះស្រាយបញ្ហាប្រឈមទាំងមូល ជួយឲ្យប្រជាពលរដ្ឋតាមជនបទ ទទួលបាននូវសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យប្រកបដោយនិរន្តភាព។

យុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈមទាំងនេះ ក៏មានលក្ខណៈស្មុគស្មាញស្រដៀងគ្នាដែរ។ យើងត្រូវមានសកម្មភាពយុទ្ធសាស្ត្រនិងសកម្មភាពពិស្តារជាច្រើន នៅតាមលំដាប់ថ្នាក់ខុសៗគ្នា ដើម្បីដោះស្រាយបញ្ហាប្រឈមនីមួយៗ។ គ្រប់សកម្មភាពទាំងអស់នេះ ទាមទារឲ្យមានកិច្ចសម្របសម្រួល ដើម្បីឲ្យសម្រេចបាននូវគោលបំណងរួមរបស់ផែនការយុទ្ធសាស្ត្រជាតិនេះ។

ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតក្រុមការងារបច្ចេកទេស វិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ដើម្បីដឹកនាំការរៀបចំធ្វើឯកសារយុទ្ធសាស្ត្រជាតិនេះ។ ការពិគ្រោះយោបល់រួមបញ្ចូលទាំងការងារចុះផ្ទាល់ក្នុងខេត្តមួយចំនួន ព្រមទាំងសិក្ខាសាលាស្តីពីការវិភាគស្ថានភាព ដោយមានការចូលរួមពីតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈកម្មការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ អភិបាលស្រុក មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត និងអង្គភាពរដ្ឋបាលមូលដ្ឋាន គ្រប់រាជធានី-ខេត្ត ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងវិស័យឯកជន។ ការពិគ្រោះយោបល់ ក៏បានរួមបញ្ចូលនូវសិក្ខាសាលាមួយចំនួន ដោយមានការចូលរួមពីអ្នកជំនាញខាងវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទសំខាន់ៗជាច្រើនរូប ដើម្បីដោះស្រាយបញ្ហាជាក់លាក់មួយចំនួន។ ការពិគ្រោះយោបល់ក៏បានរួមបញ្ចូលផងដែរ នូវការរាយការណ៍សង្ខេបជូនក្រុមការងារបច្ចេកទេស វិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# អាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក សម្រាប់សិស្ស-និស្សិតសិក្សាតាមគ្រឹះស្ថានសាធារណៈ

កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី **អាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស-និស្សិតសិក្សាតាមគ្រឹះស្ថានសាធារណៈ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួង អប់រំ យុវជន និងកីឡា។



ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើបច្ចុប្បន្នភាពលើអនុក្រឹត្យចាស់គឺអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក ដើម្បីឲ្យមានការវិវត្តស្របតាមការ រីកចម្រើនផ្នែកសេដ្ឋកិច្ច។ ការធ្វើបច្ចុប្បន្ន ភាពលើអនុក្រឹត្យចាស់នេះ បញ្ជាក់ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ជាពិសេស ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ចំពោះវិស័យអប់រំលើផ្នែកអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពរបស់អ្នកសិក្សា។

អនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំច្បាប់ស្តីពីការអប់រំ ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលតម្រូវឲ្យរដ្ឋកំណត់ការផ្តល់អហារូបករណ៍សម្រាប់អ្នកសិក្សា។ ដើម្បីឆ្លើយតបតាមមាត្រា៣០ នៃច្បាប់ស្តីពីការអប់រំដែលចែងថា "រដ្ឋត្រូវកំណត់គោលនយោបាយ ស្តីពីការផ្តល់អាហារូបករណ៍ឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សា" និងក្របខណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលចំពោះវិស័យអប់រំ ដែលរួមចំណែកអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពនិងគុណធម៌ ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹងនិងចំណេះ ធ្វើជាមូលដ្ឋាន(១)។

ក្រោយពីបានពិភាក្សាយ៉ាងផុលផុស អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យឃើញថា សេចក្តីព្រាងឯកសារនេះខុសទម្រង់ ហើយបានសម្រេចឲ្យក្រសួងសាមីយកទៅរៀបចំឡើងវិញ ដោយធ្វើជាគោលនយោបាយចង្អុលឲ្យបង្កើតជាអនុក្រឹត្យជាមុនសិន។ ចំពោះសន្ទស្សទឹកប្រាក់មិនចាំបាច់ដាក់នៅក្នុងសេចក្តីព្រាងអនុក្រឹត្យនេះទេ គួរចែងនៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកកិច្ចពិភាក្សាលើសេចក្តីព្រាងនេះ។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស-និស្សិតសិក្សាតាមគ្រឹះស្ថានសាធារណៈ។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃព្រហស្បតិ៍ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅវេលាម៉ោង ៩:០០នាទីព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** សាមីក្រសួង និងតំណាងក្រសួងពាក់ពន្ធ័មួយចំនួន ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១-សេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ ២០១៤-២០២៥។

២-សេចក្តីព្រាងច្បាប់ស្តីពីការអនុវត្តម័តយល់ព្រមលើការសន្យាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុន ស៊ីធីលុម អេសអេ។

ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចដូចខាងក្រោម៖

១-សេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ ២០១៤-២០២៥ ៖



-ឯកភាពលើទម្រង់និងខ្លឹមសាររួមរបស់សេចក្តីព្រាងសេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យនៅជនបទឆ្នាំ ២០១៤-២០២៥។

-ការផ្គត់ផ្គង់ទឹកស្អាតគឺមានសមត្ថកិច្ចពីរពាក់ព័ន្ធគ្នា រវាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងឧស្សាហកម្ម និងសិប្បកម្មថ្មី។ ដូច្នេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានណែនាំឲ្យឯកឧត្តម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ឯកឧត្តម **ហេង វង្សប៊ុនឆាត** ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងឧស្សាហកម្ម និងសិប្បកម្មថ្មី ប្រជុំពិភាក្សាកែសម្រួលម្តងទៀតពីការបែងចែកភារកិច្ចផ្គត់ផ្គង់ទឹកស្អាតរវាងក្រសួងទាំងពីរឲ្យបានច្បាស់លាស់ ដើម្បីឲ្យប្រជាជនទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់បានឆាប់រហ័សនាពេលខាងមុខ។

២-សេចក្តីព្រាងច្បាប់ស្តីពីការអនុវត្តម័តយល់ព្រមលើការសន្យាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុន ស៊ីធីលុម អេសអេ៖

-អង្គប្រជុំបានសម្រេចលើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការសន្យាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុន ស៊ីធីលុម អេសអេ ដើម្បីសុំយោបល់ពីរាជរដ្ឋាភិបាល។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានបញ្ចប់ការពិភាក្សា នៅវេលាម៉ោង ១១:៣០នាទី។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែតុលា ឆ្នាំ២០១៣*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែតុលា ឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ មិនទាន់មានតួលេខ

តារាងខាងក្រោម និងក្រាហ្វខាងក្រោម ជាតួលេខពីខែកញ្ញា។

**តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១១-២០១៣**

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា P | វិច្ឆិកា P | ធ្នូ P | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៣,៨% | ៤,០% | ៤,២% | ២,៩% |
| | ខែមុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧ | -០,២% | ០ | ០,២ | |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | ខែមុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០ | ១,១% | ០,២% | -០,២% | -០,២% | ០ | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |

P: តួលេខខែ តុលា វិច្ឆិកា ធ្នូ និងប្រចាំឆ្នាំ២០១៣ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំងអស់ទេ(មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន(ឆ្នាំ២០១១២០១២ និង២០១៣)




➡អត្រាប្តូរប្រាក់៖

| *ប្រភេទ* | គុលា២០១៣ | កញ្ញា២០១៣ | តុលា២០១២ | *ប្រភេទ* | តុលា២០១៣ | កញ្ញា២០១៣ | តុលា២០១២ |
|---|---|---|---|---|---|---|---|
| រ/ដុល្លារ | ៤០៤០៛/១$ | ៤០៦២៛/១$ | ៤០៤៣៛/១$ | បាត/ដុល្លារ | ៣១,០៨បាត/១$ | ៣២,១៣បាត/១$ | ៣០,៨៦បាត/១$ |
| រ/បាត | ១៣០៛/១បាត | ១២៦៛/១បាត | ១៣១៛/១បាត | ដុង/ដុល្លារ | ២១០៨០ដុង/១$ | ២១១២០ដុង/១$ | ២០៨៦០ដុង/១$ |
| រ/ដុង | ០,១៩២៛/១ដុង | ០,១៩២៛/១ដុង | ០,១៩៣៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែតុលាឆ្នាំ២០១៣ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១១ — ២០១៣ (ពាន់លានរៀល)




២.១.ចំណូលថវិកាជាតិ៖ អនុវត្តបាន ៤៩៤,២ពាន់លានរៀល (មធ្យមប្រចាំខែ៦៧% នៃគម្រោង)ក្នុងនោះចំណូលចរន្ត ៤៨៧,៩ពាន់លានរៀល (មធ្យមប្រចាំខែ ៩១% នៃគម្រោង) និងចំណូលមូលធន ៦,៣ ពាន់លានរៀល។

➢បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ** ថយចុះ ២៣% និងថយចុះ១៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណូលចរន្តថយចុះ២៤% ធៀបនឹងខែមុន និងថយចុះ១៤% *ធៀបនឹងខែដូចគ្នាឆ្នាំមុន*។

➢ក្នុងចំណូលចរន្ត៖

✓ចំណូលសារពើពន្ធមានចំនួន ៤១៧,១ពាន់លានរៀល ថយចុះ ២៨% ធៀបនឹងខែមុន និងថយចុះ ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន ៧០,៧ពាន់លានរៀល កើនឡើង ១៤% ធៀបនឹងខែមុននិងថយចុះ ២២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : -៣% | (-២%) | ➢ នេសាទ : -៧៤% | (+៣%) |
| ➢ ចំណូលពន្ធដារ : -៧% | (+២២%) | ➢ រុក្ខាប្រមាញ់ : -៤៣% | (+១១%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ : +៣% | (+២៤%) | ➢សម្បទានរ៉ែ : +១៤៩% | (+៣៥២%) |
| ✧ កាស៊ីណូ :+៣០% | (+៥៨%) | ➢ អាកាសចរណ៍ស៊ីវិល : +៩% | (-៥៦%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក :-៥៨% | (-៦៣%) | ➢ ផលទុននៃសកម្មភាពទេសចរណ៍ : +៧% | +៨% |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : -១៤% | (+៤%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍ :-៤% | (-៩%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ) : +១៨% | +៤២% |

២.២. *ចំណាយថវិកាជាតិ៖* អនុវត្តបានចំនួន៤២១ពាន់លានរៀល( *មធ្យមប្រចាំខែ ៥២% នៃគម្រោង*) ក្នុងនោះ ចំណាយចរន្តមានចំនួន ៣៤៥ពាន់លានរៀល ( *មធ្យមប្រចាំខែ៧១% នៃគម្រោង*) និង**ចំណាយមូលធន**ចំនួន ៧៥ ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** ថយចុះ ២៧% និងថយចុះ ៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តថយចុះ ២៤% ធៀបនឹងខែមុន និងថយចុះ ៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯចំណាយមូលធន ថយចុះ ៣៩% ធៀបនឹងខែមុន និងថយចុះ ១៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ *ថវិកាជាតិនៃខែតុលាមានអតិរេក ៧៤ពាន់លានរៀល ស្មើនឹង ១៨,៤លានដុល្លារ ស.រ.អា*។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែតុលា ឆ្នាំ២០១៣មានលក្ខណ:ដូចខាងក្រោម៖

➢រូបិយវត្ថុ $M_2$ មានចំនួន ៣០៤១២ពាន់លានរៀល កើនឡើង៣,៦% ធៀបនឹងខែមុន និងកើនឡើង ១០,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើងនៃ$M_2$ ធៀបនឹងខែមុន ជាចម្បងបណ្តាលមកពី ប្រាក់បញ្ញើចរន្ត កើនឡើង ៦% និងប្រាក់បញ្ញើជារូបិយបណ្ណកើនឡើង ៤,៣%។

➢ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន ១៩,៦% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨១,៤%។

ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុខែកញ្ញា ឆ្នាំ២០១៣




| សមាមាត្រចំនួនប្រាក់រៀល ក្នុងរូបិយវត្ថុ $M_2$ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបក្នុងនិងក្រៅធនាគារ | ១៧,២% | ១៧,៣% | ១៧,០% | ១៧,៣% | ១៦,៩% | ១៦,៨% | ១៨,១% | ១៩% | ១៩,២% | ១៩,៦% | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៧% | ១៣,៧% | ១៣,៩% | ១៤,០% | ១៣,៣% | ១៣,៤% | ១៤,៣% | ១៤,៥% | ១៤,៧% | ១៤,២% | | |

**បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែតុលា២០១៣: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន**




- ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ : មិនទាន់មានតួលេខ ។
- *ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ* ក្នុងខែនេះមានចំនួន ៨៥៩៤ពាន់លានរៀល កើនឡើង ១៤,៧% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៧,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- *ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*
- *ការផ្តល់ឥណទាន៖*

| *ផ្តល់ដោយ* | *តុលា ២០១៣* | *កញ្ញា ២០១៣* | *តុលា ២០១២* |
|---|---|---|---|
| ធនាគារពាណិជ្ជ(ពាន់លានរៀល) | ២៨៨១១ | ២៨២៥៧ | ២១៧០៧ |
| ក្នុងនោះ ជារៀល | — | ៤៥០ | ៣៨៦ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | — | ៤៦៩២ | ៣៣៦៦ |

- *អត្រាការប្រាក់ប្រចាំឆ្នាំ* នៅធនាគាពាណិជ្ជនាខែតុលា៖

| *ប្រភេទអត្រាការប្រាក់* | *តុលា២០១៣* | *កញ្ញា២០១៣* | *តុលា២០១២* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | — | ៥,៩៤% | ៥,៨៦% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | — | ១១,៩៣% | ១១,៨១% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | — | ៤,៣៨% | ៤,៤២% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | — | ១១,៣០% | ១១,៩៧% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែតុលាឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- កសិកម្ម៖
  - ✓ផលិតផលនេសាទមាន ៥៦,៥ពាន់តោន កើនឡើង ២៦% ធៀបនឹងខែមុន និងកើនឡើង១១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ឧស្សាហកម្ម៖
  - ✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា (មិនទាន់មានតួលេខ)
  - ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣៤២ លានដុល្លារថយចុះ ២៨% ធៀបនឹងខែមុនប៉ុន្តែកើនឡើង ៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ការចុះបញ្ជីរោងចក្រឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន—តុលា២០១៣ | ចំនួន—កញ្ញា២០១៣ | ចំនួន—តុលា ២០១២ |
|---|---|---|---|
| រោងចក្រថ្មីដែលបានចុះបញ្ជី | ១២ | ២៣ | ២៣ |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១០៦៤ | ១០៥២ | ៨៧០ |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៣ | ២២ | ៣០ |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១១ | ៨ | ៤៣ |

➤**សំណង់** (ការអនុញ្ញាត)៖

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៥៩៤ពាន់ម២ កើនឡើង ៦១% ធៀបនឹងខែមុន និងកើនឡើង ៨៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង២១១លានដុល្លារ កើនឡើង ៦១% ធៀបនឹងខែមុន និងកើនឡើង ១៣៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| ប្រភេទ | ពាន់ម២—តុលា២០១៣ | ពាន់ម២—កញ្ញា២០១៣ | ពាន់ម២—តុលា ២០១២ |
|---|---|---|---|
| ▪ សាធារណៈ | ២៣,៩ | ៧,៣ | ១,៥ |
| ▪ លំនៅឋាន | ៥២០,៨ | ១៣៦,៩ | ៩៩,៧ |
| ▪ ឧស្សាហកម្ម | ២៥,៦ | ២៥,១ | ១៦៥,៧ |
| អនុញ្ញាតសរុប | ៥៩៤ | ៣៧០,២ | ៣១៨,៩ |

✓ ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺ លំនៅឋាន៨៨% នៃផ្ទៃក្រឡាសរុប។

➤**ការងារ៖**

| ប្រភេទ | នាក់ : តុលា២០១៣ | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១៣៩៤ | +១៧% | -២% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៣៦១២ | +១១% | +៤១% |
| អ្នកទទួលបានការងារក្នុងប្រទេស | ២៤៣៣ | +៤៩% | +៨៣% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១១៧៩ | -២៨% | -៥% |

➤ **វិនិយោគ៖**

✓គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក. និង គ.ស.ព. (ថ្មីនិងពង្រីក) :

| ប្រភេទ | តុលា២០១៣ | កញ្ញា២០១៣ | តុលា២០១២ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៨១០ | ១១៨ | ៦៩៧,៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៦៣៧ | ៥១,៣ | ៦,២ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១៧៣ (៧) | ៦៧(១៧) | ៥០,៦(៨,៨) |
| វិស័យទេសចរណ៍ | ០ | ០ | ៦៤០,៦ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២៦ | ១៣ | ១៧ |
| បង្កើតការងារ (ពាន់នាក់) | ៣៥ | ១៩ | ២២,៣ |

➢ **សេវាកម្ម និងទេសចរណ៍៖**

✓ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| *ប្រភេទ* | *ចំនួន—តុលា២០១៣* | *ចំនួន—កញ្ញា២០១៣* | *ចំនួន—តុលា២០១២* |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២២៣ | ២៧១ | ២២៩ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៤ | ១ | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៩០ | ៣០៥ | ១៩៧ |

✓**ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៤៣១,៣ពាន់តោន ថយចុះ៩% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ១% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

| ក្នុងវង់ក្រចក : បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | |
|---|---|
| ▪ កំពង់ផែភ្នំពេញ :-១២% (-៣៣%)<br>▪ កំពង់ផែកំពង់សោម :-៧% (+១២%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង :-២២% (+១០២%)<br>(-១៦%)<br>▪ កំពង់ផែឧកញ៉ាម៉ុង : +៨% |

➢**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| *ប្រភេទ* | *ចំនួន( ពាន់នាក់ )* | *%∆ ធៀបនឹងខែមុន* | *%∆ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | | | |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៧,៤ | +២៧% | +២៣% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣៥២ | +១៩% | +៧% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៧៨ | +២៧% | +២៣% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣៣៤ | +២៧% | +២៣% |
| ✓ តាមផ្លូវអាកាស | ១៥៦ | +២៧% | +២៣% |
| ✓ តាមផ្លូវគោក និងទឹក | ១៧៨ | +២៧% | +២៣% |

## ៥) ស្ថានភាពជញ្ជូនពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលខែតុលាមានចំនួន ២៨៣៣ពាន់លានរៀល (៧០៨,២លានដុល្លារ) ថយចុះ ១% ធៀបនឹងខែមុន និងកើនឡើង១០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១៦% | +១៦% | រថយន្តសរុប (ព.ល.រ) | -១៥% | -១៧% |
| ប្រេងម៉ាស៊ូត | -១៨% | -១៧% | រថយន្តសរុប (គ្រឿង) | -២៣% | -៣៣% |
| ឧស្ម័ន | -៤% | +៣២% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -៤% | -១៥% |
| អគ្គិសនីនាំចូល | – | – | ម៉ូតូ (គ្រឿង) | +៦៩% | -៦% |
| ដែកសំណង់ | -៣៥% | -៤២% | អង្ករ | -៥៧% | -៨៨% |
| ស៊ីម៉ង់ត៍ | -៤០% | -៤០% | ផ្លែឈើនិងបន្លែ | +១៩% | +១៦% |
| គ្រឿងអេឡិចត្រូនិក | -៥៦% | -៦២% | ជីនិងថ្នាំកសិកម្ម | -៣០% | -១៥% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | +១០% | +២៦% |

➡ **ការនាំចេញ**ខែតុលាឆ្នាំ២០១៣ មានចំនួន ២០៤២ពាន់លានរៀល ស្មើនឹង៥១០,៦លានដុល្លារ ស.រ.អា. (៧២% នៃការនាំចូល) ថយចុះ ១៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៦% | +១% | ផលិតផលនេសាទ | +២៩៦% | +៥៦% |
| វាយនភណ្ឌនិងស្បែកជើង | -១៧% | +១៩% | កៅស៊ូ | -៤៣% | -៧% |
| អង្ករ | -៤% | +២៩% | | | |

➡ក្នុងខែតុលានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៧៩១ពាន់លានរៀល ស្មើនឹង ១៩៨លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែតុលា ឆ្នាំ២០១៣នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលថវិកាជាតិ | -២៣% | -១៥% | ការថយចុះធៀបនឹងខែដូចគ្នាឆ្នាំមុន ជាចម្បង បណ្តាលមកពី ការថយចុះនៃពន្ធ និងអាករគយ។ |
| ២ | ក្រុមហ៊ុនបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | -៧០% | -៥៤% | ក្នុងខែតុលា ក្រុមហ៊ុនដែលចុះបញ្ជីបង់ពន្ធដារតាមរបបពិតមានចំនួនតែ៩០ ប៉ុណ្ណោះ (ខែមុនមាន ៣០៥ និងខែតុលា ឆ្នាំមុនមាន ១៩៧) |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) ក្នុងថ្ងៃអនាគត អគ្គិសនីជាចម្បងនឹងផ្គត់ផ្គង់ដោយវារីអគ្គិសនី និងធ្យូងថ្ម រីឯការផលិតដោយប្រើប្រេងខ្មៅនឹងត្រូវកាត់បន្ថយយ៉ាងខ្លាំង។ នាពេលបច្ចុប្បន្នកម្ពុជាមានអតិរេកថាមពលអគ្គិសនីនាពេលយប់ ប៉ុន្តែមានឱនភាពនាពេលថ្ងៃ។ ការប្រើប្រាស់ថាមពលអគ្គិសនីត្រូវបានវាយតម្លៃថា មានការកើនឡើងប្រហែល ២៥%-៣០% ជារៀងរាល់ឆ្នាំ។

២) ដោយសារមានការរឹតបន្តឹងការនាំចេញជ័រកៅស៊ូបង្កក នាំឲ្យក្រុមហ៊ុនតូចៗមួយចំនួន និងអ្នកដាំកៅស៊ូគ្រួសាររងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៤/១១/១៣<br>ម៉ោង ១៨ : ០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកនៃសប្តាហ៍សិល្បៈស្តីពី "ប្រទេសចិនបច្ចុប្បន្ន" ដែលរៀបចំរួមគ្នាដោយ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា និងស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលសន្និសីទចតុមុខ។ |
| ២ | ០៥/១១/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៣ | ០៦/១១/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។<br>២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៤-២០១៦។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៦/១១/១៣<br>ម៉ោង ១៨:៣០នាទី | ចូលរួមជួបពិភាក្សាការងារជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋានឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន**។ |
| ៥ | ០៧/១១/១៣<br>ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៧/១១/១៣<br>ម៉ោង ១៧:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួល និងសហការជាមួយភាគីចិន លើគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ០៨/១១/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។<br>២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៤-២០១៦។<br>៣-បញ្ហាផ្សេងៗ៖<br>៣-១-សំណើសុំសិទ្ធិប្រទានពីរាជរដ្ឋាភិបាល ដើម្បីទៅចុះហត្ថលេខាលើវិសោធនកម្មធម្មនុញ្ញ របស់អង្គការអន្តរជាតិខាងការងារ (ILO) ឆ្នាំ១៩៨៦។<br>៣-២-សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើកិច្ចព្រមព្រៀងអាស៊ានស្តីពី បំលាស់ទីរូបវន្តបុគ្គល។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៨ | ០៩/១១/១៣<br>ម៉ោង ០៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រទានភ្លើងជ័យ ខួបអនុស្សាវរីយ៍លើកទី៦០ ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ។ |
| ៩ | ១១/១១/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីពន្លត់ភ្លើងជ័យ ខួបអនុស្សាវរីយ៍លើកទី៦០ ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ។ |
| ១០ | ១២/១១/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឱសថការី។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមការជក់ និងការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ និងកន្លែងសាធារណៈ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១១ | ១៣/១១/១៣ ម៉ោង ១៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងរាត្រីស្រមោលស ឆ្នាំ២០១៣ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា។ |
| ១២ | ១៤/១១/១៣ ម៉ោង ១០:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំផ្ទៃក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៥/១១/១៣ ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីបើកឯកសារដេញថ្លៃលើការងារសាងសង់ផ្លូវ១ខ្សែ បន្តពី ផ្លូវT5 ទៅបុរីរដ្ឋបាលខេត្តសៀមរាប ប្រវែង៩,៦៧៩ម៉ែត្រ ដោយអ៊ុតកៅស៊ូបេទីម កម្រាស់៨សង់ទីម៉ែត្រ និងប្រឡាយទទឹង៩ម៉ែត្រ អមសងខាងផ្លូវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ១៥/១១/១៣ ម៉ោង ១៥:៣០នាទី | ចូលរួមស្តាប់បទបាឋកថា ស្តីពី"រឿងក្តីរវាងថៃនិងកម្ពុជា ពាក់ព័ន្ធប្រាសាទព្រះវិហារ សំណើសុំបកស្រាយ សាលដីកាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២១/១១/១៣ ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៧/១១/១៣ ម៉ោង ០៩:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ នៅជនបទ ឆ្នាំ២០១៤-២០២៥។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ២៧/១១/១៣ ម៉ោង ១៥:៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៨ | ២៨/១១/១៣ ម៉ោង ០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារ អំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយលោក Kim អ្នកគ្រប់គ្រង ក្រុមហ៊ុន ម៉ាន់ស៊ូដេញតិច នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១១/១៣ ម៉ោង ០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងសន្និសីទថ្នាក់តំបន់ របស់អង្គការទេសចរណ៍ពិភពលោក ស្ដីពីការអភិវឌ្ឍន៍ទេសចរណ៍នៅតំបន់បេតិកភណ្ឌវប្បធម៌និងធម្មជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាល័យ អង្គរវិឡារីស៊ត ខេត្តសៀមរាប។ |
| ២ | ០៣/១១/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយកងទ័ពកងពលធំលេខ៣ និងបញ្ជាការដ្ឋានអង្គរក្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីបញ្ជាការដ្ឋានអង្គរក្ស ខេត្តព្រះវិហារ។ |
| ៣ | ១៣/១១/១៣ ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីក្រមសីលធម៌ឱសថការី។<br>២-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីវិធានការហាមការជក់ និងការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ និងកន្លែងសាធារណៈ។<br>៣-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៤/១១/១៣ ម៉ោង ១០:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំផ្ទៃក្នុងទីស្ដីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៥/១១/១៣ ម៉ោង ១៥:៣០នាទី | ចូលរួមស្ដាប់បទបាឋកថា ស្ដីពី"រឿងក្ដីរវាងថៃនិងកម្ពុជា ពាក់ព័ន្ធប្រាសាទព្រះវិហារ សំណើសុំបកស្រាយ សាលដីកាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២" ក្រោមអធិបតីភាពដ៏ ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣

## ឯកឧត្តម ឌុយ ឆៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៣/១១/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឱសថការី។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមការជក់ និងការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ និងកន្លែងសាធារណៈ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៤/១១/១៣<br>ម៉ោង ១០:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំផ្ទៃក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១៥/១១/១៣<br>ម៉ោង ១៥:៣០នាទី | ចូលរួមស្តាប់បទបាឋកថា ស្តីពី"រឿងក្តីរវាងថៃនិងកម្ពុជា ពាក់ព័ន្ធប្រាសាទព្រះវិហារ សំណើសុំបកស្រាយ សាលដីកាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២" ក្រោមអធិបតីភាពដ៏ ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣

**ឯកឧត្តម ង៉ាន់ តិរុណា អគ្គលេខាធិការ**

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១១/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងសន្និសីទថ្នាក់តំបន់ របស់អង្គការទេសចរណ៍ពិភពលោក ស្តីពីការអភិវឌ្ឍន៍ទេសចរណ៍នៅតំបន់បេតិកភណ្ឌវប្បធម៌និងធម្មជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាល័យ អង្គរវិឡារីស៊ត ខេត្តសៀមរាប។ |
| ២ | ០៣/១១/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយកងទ័ពកងពលធំលេខ៣ និងបញ្ជាការដ្ឋានអង្គរក្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីបញ្ជាការដ្ឋានអង្គរក្ស ខេត្តព្រះវិហារ។ |
| ៣ | ០៨/១១/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បី ពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។<br>២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៤-២០១៦។<br>៣-បញ្ហាផ្សេងៗ៖<br>៣-១-សំណើសុំសិទ្ធិប្រទានពីរាជរដ្ឋាភិបាល ដើម្បីទៅចុះហត្ថលេខាលើវិសោធនកម្មធម្មនុញ្ញ របស់អង្គការអន្តរជាតិខាងការងារ (ILO) ឆ្នាំ១៩៨៦។<br>៣-២-សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើកិច្ចព្រមព្រៀងអាស៊ានស្តីពី បំលាស់ទីរូបវន្តបុគ្គល។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៤ | ១៤/១១/១៣<br>ម៉ោង ១០:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំផ្ទៃក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៥/១១/១៣<br>ម៉ោង ១៥:៣០នាទី | ចូលរួមស្តាប់បទបាឋកថា ស្តីពី"រឿងក្តីរវាងថៃនិងកម្ពុជា ពាក់ព័ន្ធប្រាសាទព្រះវិហារ សំណើសុំបកស្រាយ សាលដីកាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២" ក្រោមអធិបតីភាពដ៏ ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ថាន់ តិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង វត្តមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ឆារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត កក្កដា | មន្ត្រី ក.ស.វ. |




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in